## មនុស្សចាស់

- មនុស្សចាស់មានសិទ្ធិដូចក្រុមមនុស្សវ័យដទៃទៀតដែរ ហើយពួកគេគួរត្រូវបានការពារស្មើគ្នា ក្នុងពេលមានជំងឺរាតត្បាត។ គួរផ្តោតការយកចិត្តទុកដាក់ជាពិសេស ចំពោះហានិភ័យជាក់លាក់ដែលមនុស្សចាស់ជួបប្រទះ រួមមានភាពឯកោ និងការធ្វេសប្រហែសដែលបណ្តាលមកពីការដាក់ឱ្យនៅឃ្លាតឆ្ងាយពីគ្នាខាងរាងកាយ និងការរើសអើងតាមអាយុ ក្នុងការទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងការគាំទ្រផ្សេងទៀត។
- ធានាថា ការសម្រេចចិត្តផ្អែកវេជ្ជសាស្ត្រផ្អែកលើការវាយតំលៃលើការព្យាបាលជាបុគ្គល តម្រូវការផ្នែកវេជ្ជសាស្ត្រលក្ខណៈវិនិច្ឆ័យខាងក្រមសីលធម៌ និងផ្អែកលើភស្តុតាងវិទ្យាសាស្ត្រដែលអាចរកបានល្អបំផុត និងមិនផ្អែកលើអាយុ ឬពិការភាព។